# សន្ទរកថាស្វាគមន៍
# របស់ ឯកឧត្តមបណ្ឌិត ងួន ញ៉ិល អនុប្រធានទី២ រដ្ឋសភា
# នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី ២ នៃសម័យប្រជុំពេញអង្គលើកទី៨ របស់សភាតំបន់អាស៊ី ក្រោមប្រធានបទ "ការជម្រុញសន្តិភាព ការផ្សះផ្សា និងកិច្ចសន្ទនាក្នុងតំបន់អាស៊ី"
# ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៥

---

*សូមគោរព:*

*- ឯកឧត្តម មីយ៉ាន រ៉ាហ្សា រ៉ាបានី ប្រធានព្រឹទ្ធសភាប៉ាគីស្ថាន និងជាប្រធានអង្គប្រជុំក្រុមប្រឹក្សាប្រតិបត្តិ សភាតំបន់អាស៊ី (អេ ភី អេ)*

*-ឯកឧត្តមបណ្ឌិត ម៉ាស៊ូឌ អ៊ីស្វាមី អគ្គលេខាធិការ អេភីអេ ស្តីទី*

*-ឯកឧត្តម លោកជំទាវ ប្រធាននិងសមាជិកគណៈប្រតិភូសភាសមាជិកអេភីអេ*

*-ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ជាទីមេត្រី!*

**១**-*ជាបឋម ក្នុងនាមគណៈកម្មាធិការរៀបចំមហាសន្និបាតលើកទី៨ សភាតំបន់អាស៊ី (អេ-ភី-អេ) ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ ប្រធាន និងសមាជិកសមាជិកាគណៈប្រតិភូសភាសមាជិកអេភីអេទាំងអស់ដែលបានឆ្លៀតពេលវេលាដ៏មមាញឹក និងមានតម្លៃអញ្ជើញចូលរួមមហាសន្និបាតលើកទី៨ របស់សភាតំបន់*

អាស៊ី ជាពិសេស សូមថ្លែងនូវអំណរគុណជាអនេកចំពោះការអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី២ ដ៏មានសារៈសំខាន់នាពេលនេះ។

២-វត្តមានដ៏ថ្លៃថ្លានេះជានិមិត្តរូបមួយបង្ហាញពីឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការឈានទៅសម្រេចបាននូវទស្សនៈវិស័យរបស់អេភីអេ។ បន្ថែមពីនេះ វត្តមាននេះក៏ឆ្លុះបញ្ចាំងឲ្យឃើញពីការគាំទ្រដល់សភាកម្ពុជាដែលបានទទួលកិត្តិយសធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតអេភីអេលើកទី ៨ ក្រោមប្រធានមូលបទ "ការជម្រុញសន្តិភាព ការផ្សះផ្សា និងកិច្ចសន្ទនាក្នុងតំបន់អាស៊ី" ដែលជាបុរេលក្ខណសម្រាប់ធ្វើសុខដុមកម្មពលរដ្ឋ និងប្រជាជាតិក្នុងតំបន់អាស៊ី ទទួលបាននូវសុខសន្តិភាព និងការអភិវឌ្ឍពិតប្រាកដ។

៣- ខ្ញុំសូមសម្តែងនូវការអបអរសាទរ និងគាំទ្រយ៉ាងខ្លាំងចំពោះ ឯកឧត្តមអនុប្រធានអេភីអេ ដែលទទួលបានជោគជ័យក្នុងការបោះឆ្នោតគាំទ្រឲ្យធ្វើជាប្រធានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍របស់អេភីអេ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិត ឯកឧត្តមអនុប្រធាននឹងជួយជម្រុញធ្វើឲ្យអេភីអេកាន់តែមានភាពរឹងមាំ រស់រវើក និងជោគជ័យថែមទៀតជាពិសេសជួយជម្រុញ និងពន្លឿនដំណើរការវិវត្តប្រែក្លាយ **សភាតំបន់អាស៊ី** (អេភីអេ) ឲ្យទៅជា **សភាអាស៊ី** (អេភី) នាពេលអនាគត ដែលឆ្លើយតបទៅនឹងក្តីបំណងប្រាថ្នារួមរបស់យើងទាំងអស់គ្នាក៏ដូចជាក្តីបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ អាស៊ីទាំងមូលដែលចង់រស់នៅក្នុងសុខសន្តិភាព ស្ថេរភាព វិបុលភាព សុខមាលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។

៤- ទៀតក្នុងឱកាសដ៏ថ្លៃថ្លានេះខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលេខាធិការដ្ឋាន អេភីអេ ជាពិសេស ឯកឧត្តមអគ្គលេខាធិការអេ-ភី-អេ ដែលតែងបានខិតខំប្រឹងប្រែង និងលះបង់អស់ពីកំលាំងកាយចិត្តក្នុងការជួយជ្រោមជ្រែង និងរៀបចំឯកសារពាក់ព័ន្ធសំខាន់របស់មហាសន្និបាត ជាអាទិ៍ សេចក្តីព្រាងសេចក្តីសម្រេចនានា របស់ គណៈកម្មការអចិន្ត្រៃយ៍ និងគណៈកម្មការពិសេសចំពោះកិច្ចរបស់អេភីអេ ដើម្បីដាក់ជូនអង្គមហាសន្និបាតលើកទី៨ ពិនិត្យ និងអនុម័ត។ ទន្ទឹមនឹងនេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះរដ្ឋសភានៃសាធារណ រដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ដែលជានិច្ចកាលបានជួយឧបត្ថម្ភ និងគាំទ្រទាំងផ្នែកស្មារតីនិងសំភារៈដល់ដំណើរការ និងការងាររបស់លេខាធិការដ្ឋានអេភីអេ ជាពិសេស ចំពោះការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ និងកិច្ចប្រជុំគណៈកម្មាធិការ សង្គមនិងវប្បធម៌កាលពីដើមខែវិច្ឆិកា ឆ្នាំ ២០១៥ កន្លងទៅប្រកបដោយជោគជ័យ។

*សម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី ជាទីមេត្រី*

៥-សភាកម្ពុជា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទាំងមូល មានកិត្តិយស និងក្តីសោមនស្សរីករាយ ប្រកបដោយមោទនភាពក្នុងការធ្វើជាម្ចាស់ផ្ទះទទួលរៀបចំ និងធ្វើជាប្រធានមហាសន្និបាតអេភីអេលើកទី ៨ និងលើកទី ៩ នាឆ្នាំ ២០១៥ និងឆ្នាំ ២០១៦ ដែលនេះឆ្លុះបញ្ចាំងឲ្យពិភពលោកឃើញ កាន់តែច្បាស់អំពីតួនាទីដ៏សំខាន់របស់កម្ពុជាក្នុងការងារការទូតសភា និងការរួមចំណែកយ៉ាងធំធេងរបស់សភាកម្ពុជាក្នុងដំណើរការធ្វើសមហរណកម្មតំបន់ និងពិភពលោក។

៦- "ការជម្រុញសន្តិភាព ការផ្សះផ្សា និងការសន្ទនាក្នុងតំបន់អាស៊ី" ជាប្រធានបទមួយដ៏មានសារសំខាន់ និងសមស្របបំផុតទៅនឹងបរិបទតំបន់ និងពិភពលោក បច្ចុប្បន្ន។ ប្រធានបទនៃមហាសន្និបាតលើកទី៨ នេះ ក៏មានទំនាក់ទំនងយ៉ាងជិត ស្និតទៅនឹងមូលបទនៃមហាសន្និបាតលើកទី៧ និងខ្លឹមសារនៃប្រធានបទនៃកិច្ចប្រជុំរបស់គណៈកម្មការនានារបស់អេភីអេ។ ជារួមគឺសំដៅទទួលបានសុខសន្តិភាព ស្ថេរភាព និងការដោះស្រាយរាល់បញ្ហាប្រឈមនានាទាំងក្នុងតំបន់និងពិភពលោក ជាលក្ខណៈទ្វេភាគី ឬ ពហុភាគី ប្រកបដោយសន្តិវិធី និងជៀសផុតពីការប្រើប្រាស់មធ្យោបាយយោធា ដែលនឹងធ្វើឲ្យអន្តរាយ និងវិនាសហិនហោចដល់សង្គម និងប្រទេសជាតិ។

៧-កម្ពុជាចាត់ទុក "សន្តិភាព ការផ្សះផ្សា និងកិច្ចសន្ទនា" ជាកត្តាសំខាន់ចាំបាច់និងជាបុរេលក្ខ័ណ្ឌក្នុងការ កសាង និងអភិវឌ្ឍប្រទេស និងសង្គមជាតិមួយឲ្យមានភាពរីកចំរើន ជឿនលឿន ប្រកបដោយនិរន្តភាព និងភាពសុខដុមរម្យនា។

៨- ខ្ញុំមានសុទិដ្ឋិនិយមថា កិប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី ២ នេះ នឹងទទួលបានលទ្ធផល និងការឯកភាគ្នាជាឯកច្ឆ័នលើសេចក្តីព្រាងរបៀបវារៈទាំងអស់ដែលយើងនឹងពិភាក្សាក្នុងពេលបន្តិចទៀតនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សង្ឃឹមផងដែរថា កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំគណៈកម្មការផ្សេងៗរបស់អេភីអេ ក្នុងរយៈពេល៣ ថ្ងៃខាងមុខនេះ នឹងទទួលបានការចូលរួមយ៉ាងសកម្ម និងរស់រវើក ដោយមានកិច្ចពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ ទស្សនៈ និងយោបល់ពីគ្នាទៅវិញទៅមកសំដៅធ្វើឲ្យមហាសន្និបាតនេះទទួលបានជោគជ័យនិងលទ្ធផលផ្លែផ្កា។

៩-ខ្ញុំសូមរង់ចាំ និងទទួលស្វាគមន៍ជានិច្ចចំពោះសំណើ ទស្សនៈ និងយោបល់ដ៏មានតម្លៃដើម្បីធ្វើយ៉ាងណាឲ្យមហាសន្និបាតលើកទី៨ កាន់តែទទួលបានជោគជ័យ និងជាពិសេស ធ្វើឲ្យសេចក្តីសម្រេចនានាដែលនឹងអនុម័តដោយមហាសន្និបាតនេះកាន់តែមានភាពសមស្រប និងអនុវត្តបាន ដែលឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងរបស់តំបន់អាស៊ី។

១០- ជាទីបញ្ចប់តាងនាមឲ្យគណៈកម្មាធិការរៀបចំមហាសន្និបាត ខ្ញុំសូមថ្លែងអំណរគុណជាថ្មីចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិនាពេលនេះ និងសូមគោរពជូនពរដល់ភ្ញៀវកិត្តិយសទាំងអស់សូមទទួលបាននូវសុខភាពល្អ និងជោគជ័យគ្រប់ភារៈកិច្ច។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**

Welcoming Remarks

**Honorable Dr. NGUON Nhel, Second Vice-President**

**of National Assembly of the Kingdom of Cambodia and Chairman**

**of the Organizing Committee of the 8th Asian Parliamentary Assembly**

**At the 2nd Executive Council Meeting of the 8th APA General Assembly**

**Theme: "Promoting Peace, Reconciliation and Dialogue in Asia"**

**Date: 8th December 2015**

**Venue: Sokha Phnom Penh Hotel and Residence**

- *Honorable MIAN Raza Rabbani, President of the Pakistan Senate and Chairman of the Second Executive Council Meeting;*
- *His Excellency Dr. Masud Eslami, Acting Secretary-General of APA ;*
- *Honorable Heads and Members of Delegations of APA Member Parliaments*
- *Excellencies, National and International Distinguished Guests, Ladies and Gentlemen;*

1. First of all, on behalf of the Organizing Committee of the 8th Plenary Session of the Asian Parliamentary Assembly (APA), I wish to express my great pleasure and warm welcome to all Honorable Heads and Members of Delegations of APA Member Parliaments for your valuable presence to attend the 8th Plenary Session of APA. In particular, I would like to sincerely thank all honorable delegates for participating in today's important meeting of the Second Executive Council.

2. Your presence is an indicative of your strong commitment towards attaining our APA vision. Your presence also reflects your support for the Cambodian National Assembly, which is honored to host the 8th APA General Assembly, which is taking place under the theme "Promoting Peace, Reconciliation and Dialogue in Asia," a precondition for harmonizing peoples and nations in Asia for genuine peace and development.
3. I would like to congratulate and strongly support the Honourable Vice Presidents of APA who have been successfully elected as Chairmen of the APA Standing Committees. I strongly believe that under their wise leadership and strong commitment, they will help to promote APA to be more dynamic and successful, in particular to accelerate and foster the transformation of the Asian Parliamentary Assembly (APA) into the Asian Parliament (AP) in the near future, which is a response to our common aspirations and goals for all people in Asia to be living in peace, stability, prosperity and sustainable development.
4. Taking this opportunity, I wish to deeply thank the APA Secretariat, especially His Excellency Acting Secretary General for his great leadership and best efforts to support and help the Cambodian National Assembly with technical assistance in organizing this Plenary Session from the outset, such as coordination and processing documents including draft resolutions of the Standing Committees, Ad-Hoc Committees and Special Committee to be submitted to the Plenary for consideration and adoption. I would also like to express my deep thanks to the Consultative Assembly of the Islamic Republic of Iran for its on-going support, both technically and financially for the APA Secretariat, especially for the successful hosting the First Executive

Council meeting and the meeting of the Standing Committee on Social and Cultural Affairs in Iran early November 2015.

**Samdech, Honorable Delegates**

**Excellencies, Ladies and Gentlemen**

5. The Cambodian Parliament, the Royal Government and the people of Cambodia have the great honor and pleasure to be the host of the 8th and 9th Plenary Session of APA in 2015 and 2016. This shows the whole world the clearer roles that the Cambodian Parliament plays in parliamentary diplomacy, providing substantial contributions to regional and global integration.

6. "Promoting Peace, Reconciliation and Dialogue in Asia" is a very important and relevant topic in the current regional and global context. The theme of the 8th Plenary Assembly is also connected to the last year's 7th APA Plenary Session and to the work of the various Standing Committees. It aims to achieve genuine peace, stability and resolution to all regional and global challenging, through either bilateral or multi-lateral mechanisms and peaceful dialogue; without the use of military or force that may lead the destruction of societies and nations.

7. Cambodia considers "Peace, Reconciliation and Dialogue" as key factors and preconditions for building and developing a society and country with prosperity, sustainable development and harmony.

8. I am optimistic that this 2nd Executive Meeting will come up with concrete decisions and solutions to all the items placed on its agenda. I also expect that the upcoming three day meetings of the Plenary, the

APA Standing Committees and other related meetings will be active and interactive through discussions and exchanges of experiences and idea to help make the 8th Plenary Session a success.

9. I look forward to hearing your valuable ideas and proposals to make the resolutions even more viable for prospective implementation, reflecting the concrete situation in Asia.

10. To conclude my remarks, on behalf of the Organizing Committee, I once again would like to express my sincere thanks and profound gratitude to all honorable delegates and distinguished participants for your valuable attendance at this Executive Council Meeting. I finally would like to convey to all of you best wishes, good health and success in your noble mission.

Thank you for your kind attention.